00641027

E14/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១១

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 31 / 01 / 2011
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ទៅនឹងសេចក្ដីសន្និដ្ឋាន របស់សហព្រះរាជអាជ្ញាចំពោះសំណើសុំដើម្បីកំណត់អំពីកាលបរិច្ឆេទកំណត់**

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|---|
| សហមេធាវីរបស់ អៀង ធីរិទ្ធ | អង្គជំនុំជម្រះសាលាដំបូង | សហព្រះរាជអាជ្ញា |
| លោក ផាត់ ពៅសៀង | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| កញ្ញា Diana ELLIS QC | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី |
| | ចៅក្រម Silvia CARTWRIGHT | ពេជ្រ អង្គ |
| | ចៅក្រម Jean-Marc LAVERGNE | Elisabeth SIMONNEAU FORT |

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ (ជនជាប់ចោទ) និង មេធាវីការពារក្តីជនជាប់ចោទ លោកនួន ជា បានដាក់ "សំណើបន្ទាន់ដើម្បីកំណត់អំពីកាលបរិច្ឆេទកំណត់"(សំណើ)[1]ហើយដែលសហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១(ចម្លើយតប)[2] ។ តទៅនេះ មេធាវីការពារក្តីសូមដាក់ជូនសេចក្តីសន្និដ្ឋានតបរបស់ខ្លួនដោយអនុលោមតាម មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក។

២. មេធាវីការពារក្តីនឹងកំរិតខ្លួនឯងនៅក្នុងសេចក្តីសន្និដ្ឋានតបនេះដើម្បីលើកឡើងតែបញ្ហាទាំងឡាយណាដែលមិនទាន់បានលើកឡើងនៅក្នុងសំណើរបស់ខ្លួនប៉ុណ្ណោះ។

## II អំណះអំណាង

៣. សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា សំណើរបស់មេធាវីការពារក្តីនោះខកខានមិនបានបង្ហាញអំពីអវត្តមាននៃសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដែលមានសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះ[3]ថានឹងមានផលប៉ះពាល់ទៅលើលទ្ធភាពរបស់ខ្លួនយ៉ាងដូចម្តេច ដើម្បីចងក្រងបញ្ជីឈ្មោះសាក្សី និងតាក់តែងអញ្ញត្រកម្មនោះ។

៤. អំណះអំណាងសំខាន់បំផុតដែលលើកឡើងដោយមេធាវីការពារក្តីគឺថា: សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍នោះមិនមានអនុភាពដូចជា "សេចក្តីសម្រេច"បានទេ ហេតុដូច្នេះ កាលបរិច្ឆេទកំណត់មិនទាន់ត្រូវបានចាប់ផ្តើមគិតនៅឡើយទេ។ នៅមុនពេលមេធាវីការពារក្តីដាក់នូវអំណះអំណាងរបស់ខ្លួននោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាខ្លួនឯងថាអង្គជំនុំជម្រះសាលាដំបូង

---

[1] សំណើបន្ទាន់របស់មេធាវីការពារក្តីស្នើសុំកំណត់កាលបរិច្ឆេទកំណត់ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E14

[2] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ និង នួន ជាសុំឲ្យបញ្ជាក់ថ្ងៃផុតកំណត់, ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E14/1។ឯកសារនេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១១ ។

[3] អបជ, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ (សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍)។

បានទទួលបណ្តឹង ហើយថ្ងៃបន្ទាប់មកទៀតនោះ មេធាវីការពារក្តីក៏បានដាក់សំណើនោះភ្លាមៗដែរៗ។ ដោយសារតែ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាខ្លួនបានទទួលបណ្តឹងហើយនោះ ដូច្នេះទើបមេធាវីការពារក្តីចាប់ផ្តើមដាក់ឯកសារផ្សេងៗនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ចំណុចនេះវាមិនមានន័យថាមេធាវីការពារក្តី "បានទទួលយកទាំងស្រុងថា សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះមានអនុភាពជា "សេចក្តីសម្រេច" ស្របតាមន័យនៃវិធាន ៧៧ នៃវិធានផ្ទៃក្នុងដូចតាមការអះអាងរបស់សហព្រះរាជអាជ្ញា[4]នោះទេ ក៏ប៉ុន្តែមេធាវីការពារក្តីមិនមានបំណងរារាំងឬធ្វើពហិការដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ។

៥. មេធាវីការពារក្តីយល់ឃើញថាប្រសិនបើសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះមិនត្រូវបានគេផ្តល់ឱ្យនោះទេ ហើយត្រូវបានគេគិតថាជាផ្នែកនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្របតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងនោះ វាប្រាកដជាមាននូវសម្អាងហេតុទាំងនោះជាមិនខាន ហេតុដូច្នេះសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍នេះពិតជាមិនចាំបាច់។ តាមពិតទៅ សហព្រះរាជអាជ្ញាយល់ឃើញនូវចំណុចនេះ ដោយលើកឡើងថា "មិនមានហេតុផលណាមួយដែលបង្ហាញថាសេចក្តីសម្រេចពេញលេញរបស់អង្គបុរេជំនុំជម្រះនឹងធ្វើឱ្យប៉ះពាល់ដល់អញ្ញត្រកម្មរបស់ជនត្រូវចោទដែលនឹងត្រូវធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះយ៉ាងដូចម្តេចនោះទេ"[5]។

៦. សម្អាងហេតុរបស់អង្គបុរេជំនុំជម្រះត្រូវបានគេគិតថាមានសារៈសំខាន់ណាស់ចំពោះមេធាវីការពារក្តីដើម្បីតាក់តែងអញ្ញត្រកម្ម ហេតុដូច្នេះ ការដាក់ " សារណាបន្ថែម" ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[6] គឺវាមិនមែនជាដំណោះស្រាយមួយនោះទេ។ ម្យ៉ាងវិញទៀត ការចងក្រងបញ្ជីឈ្មោះសាក្សីត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់តាមរយៈសម្អាងហេតុនេះតែម្តង ទោះបីជាវាមានវិសាលភាពតិចតួចក៏ដោយ ក៏សមាសភាពនៃបញ្ជីនោះនឹងអាចផ្អែកលើការកំណត់នៃភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គបុរេជំនុំជម្រះដែលដំណើការវាយតម្លៃនេះមិនទាន់ត្រូវបានបញ្ចប់ដោយអង្គបុរេជំនុំជម្រះនៅឡើយដែរ។ លើសពីនេះទៀតនោះ មេធាវីការពារក្តី

---

[4] កថាខណ្ឌ ៥ នៃសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ។

[5] កថាខណ្ឌ ៦ នៃសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ។

[6] កថាខណ្ឌ ៨ នៃសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ។

សន្មត់ថាយ៉ាងហោចណាស់ក៏ អង្គជំនុំជម្រះសាលាដំបូងអាចយកសេចក្ដីណែនាំពីសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះចំពោះសេចក្ដីសម្រេចអំពីយុត្តាធិការនៅក្នុងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះខ្លះដែរ។

## III. សេចក្ដីសន្និដ្ឋាន

៧. ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅខាងលើ មេធាវីការពារក្ដីសូមស្នើអង្គជំនុំជម្រះសាលាដំបូងដើម្បីបញ្ជាក់អំពីកាលបរិច្ឆេទកំណត់ដែលបានតម្រូវនៅក្នុងវិធាន ៨០ និង ៨៩ នៃវិធានផ្ទៃក្នុង, និងទីពីរស្នើសុំអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់អំពីកាលបរិច្ឆេទកំណត់ទាំងនេះត្រូវចាប់ផ្ដើមគិតពីថ្ងៃដែលអង្គបុរេជំនុំជម្រះបានផ្ដល់សម្អាងហេតុសំរាប់សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន។ ដោយពិចារណាទៅលើលក្ខណៈនៃសំណើនេះ មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូងចេញដីកានេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA |